ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៨៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ភារកិច្ច និងបេសកកម្មរបស់ក្រុមប្រឹក្សា

## កំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើត ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-បានឃើញព្រះរាជក្រិត្យលេខ នស/រកត/០៦០២/១៩៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការ បង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ

-តាមសំណើរបស់សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ

**សំរេច**

### មាត្រា ១.-

អនុក្រឹត្យនេះកំណត់ភារកិច្ច និងបេសកកម្មរបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ ។

### មាត្រា ២.-

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធមិមានភារកិច្ច និងបេសកកម្មដូចតទៅ :

១-លើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវទស្សនទាននៃកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធមិ និង យុទ្ធសាស្ត្រគំរោងផែនការ ព្រមទាំងកម្មវិធីការងារ សំរាប់ធ្វើឱ្យសំរេចគោលដៅទាំងឡាយនៃទស្សនទាន នោះ ។

២-អនុវត្តសេចក្តីណែនាំ ដែលទទួលបានពីឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងការដាក់ឱ្យដំណើរការនូវយុទ្ធសាស្ត្រ និងកម្មវិធីកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

៣-អនុតម័តវិធានការចាំបាច់ទាំងឡាយណា ក្នុងការដាក់ឱ្យដំណើរការកំណែរទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

៤-ចេញសេចក្តីសំរេច និងសេចក្តីណែនាំចាំបាច់ដល់គ្រប់ក្រសួង ស្ថាប័នយុត្តិធម៌ និងស្ថាប័ននានា ដើម្បីដឹកនាំ និងជំរុញដំណើរការកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

៥-សំរបសំរួលបណ្តាសកម្មភាពរបស់ក្រសួង ស្ថាប័នយុត្តិធម៌ និងស្ថាប័ននានា ដែលទាក់ទងទៅនឹងកម្មវិធីកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

៦-តាមដានការអនុវត្តកម្មវិធីកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅតាមក្រសួង ស្ថាប័នយុត្តិធម៌ស្ថាប័ននានា និងរាយការណ៍ពីលទ្ធផលទទួលបាន ព្រមទាំងសំណូមពរពាក់ព័ន្ធនានា ជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

៧-ទំនាក់ទំនង សំរបសំរួល ដើម្បីកេណ្ឌធនធានពីរដ្ឋ និងជំនួយអន្តរជាតិចាំបាច់

៨-ជំរុញការងារផ្សព្វផ្សាយព័ត៌មាន ស្តីពីសកម្មភាព និងសមិទ្ធផលនៃការងារកំណែទំរង់នេះ

៩-បង្កលក្ខណៈ និងរៀបចំឱ្យមានការចូលរួមផ្តល់យោបល់ពីអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលនានា

១០-អនុវត្តរាល់ភារកិច្ចផ្សេងៗទៀត ដែលឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋប្រគល់ឱ្យ ។

**មាត្រា ៣.-**

ក្នុងការបំពេញភារកិច្ច និងបេសកកម្មខាងលើនេះក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានសិទ្ធិប្រើត្រាទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៤.-**

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានខ្ទង់ថវិកាដោយឡែកនៅក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៥.-**

ធនធាន និងថវិការបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវបានផ្គត់ផ្គង់ដោយ :

- វិភាគទាននៃថវិកាជាតិ
- ហិរញ្ញប្បទានបានមកពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

**មាត្រា ៦.-**

បទប្បញ្ញាត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ស្ថាប័នដែលពាក់ព័ន្ធ និងសហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋ**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

***បានយកសេចក្តីជម្រាបជូន***

***សម្តេចនាយករដ្ឋមន្ត្រី "ដើម្បីសុំហត្ថលេខា"***

***សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌***

***ហត្ថលេខា*** ***ហត្ថលេខា***

**ឱក មន្នី** **សុខ អាន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ដូចមាត្រា ៨

-ឯកសារ-កាលប្បវត្តិ